# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ២៧២,២២២ ដុល្លារអាមេរិកដើម្បីពង្រឹងសមត្ថភាពធ្វើរោគវិនិច្ឆ័យជំងឺរបេងនៅតំបន់ជនបទនៃប្រទេសកម្ពុជា



ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ២៧២,២២២ ដុល្លាអាមេរិកដល់សមាគមកំចាត់រោគរបេងជប៉ុន(JATA) សម្រាប់គម្រោងពង្រឹងសមត្ថភាពធ្វើរោគវិនិច្ឆ័យជំងឺរបេង ក្នុងស្រុកប្រតិបត្តិពារាំង ខេត្ត ព្រៃវែង។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក សៀក គុណ រ័ត្ន ប្រធានគម្រោងរបស់អង្គការ JATA នៅស្ថានទូតជប៉ុន។

ក្នុងគម្រោងនេះ JATAនឹងបំពាក់សម្ភារៈបរិក្ខារពេទ្យសម្រាប់ធ្វើរោគវិច្ឆ័យជំងឺរបេងដែលរួមមានម៉ាស៊ីនថតដោយកាំរស្មីអ៊ិចឌីជីថល និងមីក្រូទស្សន៍ក្នុងមន្ទីរពេទ្យបង្អែកពារាំង ក្នុងស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង។ តាមរយៈគម្រោងនេះ ប្រជាជនជាច្រើនក្នុងតំបន់គោលដៅ នឹងទទួលបានការធ្វើរោគវិនិច្ឆ័យរកជំងឺរបេង ដើម្បីកាត់បន្ថយអត្រាចម្លងជំងឺរបេង។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្ថាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង២០.៤ លានដុល្លាអាមេរិកដល់គម្រោងចំនួន ៧៧ គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យ សុខាភិបាល វិស័យ កសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោង នេះគឺជាគម្រោងទី៧តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៣ របស់ជប៉ុន (មេសា២០១៣ដល់មិនា២០១៤)។




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៩-៣៣០

អ៊ីមែលៈ eco.jpn@.pp.mofa.go.jp

គេហទំព័រៈ http://www.kh.emb-japan.go.jp